**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ០១...សរ.ណ.**

# សារាចរ

# ស្តីពី

# វិធាន និងនីតិវិធី នៃការកែសម្រួល និងវិចារណកម្មស្ថាប័ន នៃរាជរដ្ឋាភិបាល

ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តន៍ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧ /៣១៣ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងការកែសម្រួលនិងវិចារណកម្មស្ថាប័ន រាជរដ្ឋាភិបាលធ្វើការណែនាំដល់ក្រសួងដែលមានសមត្ថកិច្ចពាក់ព័ន្ធដូចខាងក្រោម អំពីវិធាននិងនីតិវិធី នៃការកែសម្រួលនិងវិចារណកម្មស្ថាប័ន រួមមានជាអាទិ៍ ការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ច ដូចតទៅ÷

**ក. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានភារកិច្ចរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធ្វើការកែសម្រួលព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងទៀត សំដៅផ្ទេរសមត្ថកិច្ចនិងការទទួលខុសត្រូវលើអាជ្ញាធរអប្សរា អាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក និងគណៈកម្មការជាតិយូណេស្កូកម្ពុជាពីទីស្តីការគណៈរដ្ឋមន្ត្រី មកនៅក្រោមក្រសួងវប្បធម៌និងវិចិត្រសិល្បៈវិញ ។

**ខ. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានភារកិច្ចរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធ្វើការកែសម្រួលព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត សំដៅផ្ទេរសមត្ថកិច្ចនិងការទទួលខុសត្រូវលើក្រុមប្រឹក្សាគណៈវិស្វករកម្ពុជាពីទីស្តីការគណៈរដ្ឋមន្ត្រី មកនៅក្រោមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈវិញ ។

**គ. ក្រសួងអប់រំយុវជន និងកីឡា**

ក្រសួងអប់រំយុវជន និងកីឡាដែលទទួលបានការផ្ទេរសមត្ថកិច្ចនិងការទទួលខុសត្រូវលើកាយវប្បកម្ម... កាយវីរិទ្ធិជាតិកម្ពុជា មានភារកិច្ចរៀបចំតាក់តែងសេចក្តីព្រាងព្រះរាជក្រឹត្យនិងអនុក្រឹត្យពាក់ព័ន្ធការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅរបស់កាយវីរិទ្ធិជាតិកម្ពុជា ដោយមានសម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធានកាកបាទក្រហមកម្ពុជា ជាគុរុគណ នៃកាយវីរិទ្ធិជាតិកម្ពុជា ហើយរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ជាប្រធានក្រុមប្រឹក្សាជាតិកាយវីរិទ្ធិជាតិកម្ពុជា ។

**ឃ. ការបន្តនិរន្តរភាព នៃកិច្ចដំណើរការការងារ**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលបានការផ្ទេរសមត្ថកិច្ចនិងការទទួលខុសត្រូវនេះ មានភារកិច្ចធានានិរន្តរភាព នៃកិច្ចដំណើរការការងាររបស់អាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលត្រូវបានផ្ទេរនេះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**ង. ការផ្ទេរឥណទានថវិកា**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំនីតិវិធីចាំបាច់ ដើម្បីផ្ទេរឥណទានថវិការបស់អាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលបានការផ្ទេរសមត្ថកិច្ចនិងការទទួលខុសត្រូវនេះ ដោយអនុលោមតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី៣១ខែ[illegible] ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ